# ព្រឹត្តិបត្រប្រចាំត្រីមាសទី១

*ទឹកស្អាតសម្រាប់មនុស្សគ្រប់រូប*

ខែមករា ដល់ ខែមីនា ឆ្នាំ២០២៤

## ១. បច្ចុប្បន្នភាពសមាគម

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ជាសមាគមអព្យាក្រឹត មិនស្វែងរកប្រាក់កម្រៃជាឯកជនមិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើនយោបាយ មិនធ្វើជាឧបករណ៍របស់គណបក្សនយោបាយ ក្នុងនោះមិនផ្តល់ជាសម្ភារ ហិរញ្ញវត្ថុ ធនធានមនុស្ស ដើម្បីគាំទ្រគណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រណាមួយឡើយ។ សមាគមបម្រើឱ្យផលប្រយោជន៍សមាជិក និងផលប្រយោជន៍សាធារណៈតាមលទ្ធភាពដែលសមាគមអាចចូលរួមបាន។

សមាគមបង្កើតឡើងនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១ ដោយក្រុមអ្នកផ្គត់ផ្គង់ទឹកស្អាតឯកជនមួយក្រុមមានគ្នាប្រមាណជា ២០នាក់ ក្រោមជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ របស់គម្រោង អេមអេស អេម អ៊ី កម្ពុជា (MSME) ឧបត្ថម្ភដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) និងបានចុះបញ្ជីសមាគមជាផ្លូវការនៅក្រសួងមហាផ្ទៃ តាមសេចក្តីជូនដំណឹងលេខ: ១០៧៧ សជណ របស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១២។ ក្រសួងមហាផ្ទៃចេញសេចក្តីប្រកាសលេខ: ២៩០១ ប្រក ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២១ សម្រេចចុះឈ្មោះសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ឡើងវិញក្នុងបញ្ជីសមាគមសម្រាប់នីតិបុគ្គល នៅក្រសួងមហាផ្ទៃ ដោយមានអាសយដ្ឋាននៃទីស្នាក់ការកណ្តាលស្ថិតនៅអគារ F ជាន់ទី២ បន្ទប់លេខ ២៦៩ នៃមជ្ឈមណ្ឌលភ្នំពេញ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

សមាគមបង្កើតឡើងក្នុងគោលបំណងប្រមូលផ្តុំអ្នករួមអាជីព ឬរួមវិជ្ជាជីវៈទាំងអស់ក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនប្រកាន់និន្នាការនយោបាយអ្វីឡើយ។

ត្រឹមបំណាច់ត្រីមាសទី១ ឆ្នាំ២០២៤ សមាគមមានសមាជិកសរុបចំនួន ៣២១ស្ថានីយ/ក្រុមហ៊ុន ដែលបាននឹងកំពុងប្រតិបត្តិការនៅក្នុង ២៣រាជធានី/ខេត្ត/ក្រុង នៃព្រះរាជាណាចក្រកម្ពុជា ក្នុងនោះមានសមាជិកជាប្រតិបត្តិករផ្គត់ផ្គត់ទឹកស្អាតចំនួន ២៨២ស្ថានីយ និងសមាជិកជាក្រុមហ៊ុនផ្គត់ផ្គង់លើវិស័យទឹកស្អាតចំនួន ៣៩ក្រុមហ៊ុន។

## ១. អំពីសមាជិកភាព

ក្នុងត្រីមាសទី១ នៃឆ្នាំ២០២៤ មានស្ថានីយផ្គត់ផ្គង់ទឹកស្អាតចំនួន៥ និងសមាជិកគាំទ្រជាក្រុមហ៊ុនចំនួន ២ បានចូលជាសមាជិករបស់សមាគមរួមមាន៖

| ល.រ | ឈ្មោះស្ថានីយផ្គត់ផ្គង់ទឹកស្អាត | ខេត្ត |
|---|---|---|
| ១ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត សាមគ្គីមានជ័យ | កំពង់ឆ្នាំង |
| ២ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ឃុំសាលាវិស័យ | កំពង់ធំ |
| ៣ | ក្រុមហ៊ុន អេស៊ា ស្វាយរៀង វ៉ធើរ ឯ.ក | ស្វាយរៀង |
| ៤ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត បឹងខ្នារ វង់ ធារី | ពោធិ៍សាត់ |
| ៥ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត រ៉ុមលីលី ទឹកជ្រៅ | ត្បូងឃ្មុំ |
| | សរុបៈ ៥ ស្ថានីយផ្គត់ផ្គង់ទឹកស្អាត | |

| ល.រ | ឈ្មោះសមាជិកគាំទ្រ |
|---|---|
| ១ | ក្រុមហ៊ុន អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី |
| ២ | ក្រុមហ៊ុន ផាម អេឡិកទ្រិក សឹលូសិន ឯ.ក |
| | សរុបៈ ២ ក្រុមហ៊ុន |

## ២. អភិបាលកិច្ច

### ២.១ សន្និបាតប្រចាំឆ្នាំ២០២៣

ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤ សមាគមបានរៀបចំសន្និបាតលើកទី១២ ក្នុងគោលបំណង៖

១. អបអរសាទរសមិទ្ធិផលរបស់ក្រុមប្រឹក្សាភិបាលសមាគមអាណត្តិទី៣ (២០២០-២០២៣)
២. ជ្រើសរើសក្រុមប្រឹក្សាភិបាលសមាគមសម្រាប់ អាណត្តិទី២ (២០២៤ - ២០២៧)
៣. អបអរសាទរសមិទ្ធិផលរបស់សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជាក្នុងឆ្នាំ២០២៣ និងរៀបចំផែនការការងារប្រចាំឆ្នាំ សម្រាប់ ឆ្នាំ២០២៤
៤. បង្កើនទំនាក់ទំនងសមាជិកសមាគមឱ្យកាន់តែប្រសើរឡើង និងចែករំលែកបច្ចេកវិទ្យាថ្មីៗ។

អង្គសន្និតបាតមានការអញ្ជើញជាគណៈអធិបតីដ៏ខ្ពង់ខ្ពស់ ឯកឧត្តម ហែម វណ្ណឌី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងឯកឧត្តម ចាស់ស៊ីន វ៉ាយអេជ ឯកអគ្គរាជទូតអូស្ត្រាលី ប្រចាំប្រទេសកម្ពុជា។



*រូបភាពទី 1-កម្មវិធីបើកសន្និបាតលើកទី១២*

សន្និបាតទទួលបានការសហការឧបត្ថម្ភពីអង្គការ **Water.org** កម្មវិធី **CAPRED** និងក្រុមហ៊ុន ១៩ ផ្សេងទៀតរួមមាន៖ ១.ក្រុមហ៊ុន ធី អ៊ី អឹម ខូអិលធីឌី (TEM) ២.ក្រុមហ៊ុនវ៉តធើម៉ិច ថេកណូឡូជី (**Watermech)** ៣.**Representative Office of Fuji Electric Co., Ltd** ៤.សហគ្រាសអ៊ី-ផៅវ័រ ស៊ីស៊ីអិល (**E-Power)** ៥.អិកវ៉ធើរថេកណូឡូជី(X-Water) ៦.ធីស៊ីយូប៉ូលីអេធើប្រាយ (TCU) ៧.ក្រុមហ៊ុនភ្នំពេញប្លាស្ទិចប្រូដាក់(**Phnom Penh Plastic)** ៨.ក្រុមហ៊ុនធីនីមិុច (**Dhinimex)** ៩.ក្រុមហ៊ុនវ៉ធើរ ផាតនើរ (ខេមបូឌា) ឯ.ក ១០.ក្រុមហ៊ុនដៃគូទឹក (**Water Partners**) ១១.ក្រុមហ៊ុន ខេស៊ីអអាយ អ៊ិនធើណេសិនណល ខូអបភើរេសិន ឯ.ក (KCRI) ១២.ក្រុមហ៊ុន លេសសូ (ខេមបូឌា) ត្រេឌីង ឯ.ក (**LESSO)** ១៣.**Petram Design International** ១៤.ក្រុមហ៊ុន ឥន្ទនូ ខេមបូឌាត្រេឌីង ១៥.**GEOCRAFT Co.,Ltd** ១៦.**Foreign Trade Bank of Cambodia** ១៧. ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ១៨. **Stone Family Foundation** និង ១៩.មីក្រូហិរញ្ញវត្ថុ **LOLC**។



*រូបភាពទី 2-សមាជិក សមាជិកាក្នុងសន្និបាតលើកទី១២*

សន្និបាតមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំក្រសួង ឧរបន និងតំណាងមកពីក្រសួងអភិវឌ្ឍន៍ជនបទ ស្ថានទូតចក្រភពអង់គ្លេស ស្ថានទូតអូស្ត្រាលីប្រចាំនៅកម្ពុជា អង្គការ Water.org កម្មវិធី CAPRED ដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ ក្រុមប្រឹក្សាភិបាល គណៈកម្មាធិការប្រតិបត្តិ ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនផ្គត់ផ្គង់ផលិតផល និងសេវាកម្ម និងសមាជិកជាប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត សរុបចំនួន ៤១៥នាក់ (ស្រី ១១៥នាក់)។ ទន្ទឹមនឹងនោះ ក៏មានការតាំងបង្ហាញផលិតផល និងសេវាកម្មពាក់ព័ន្ធនឹងវិស័យទឹកស្អាតផងដែរ។

សន្និបាតបានធ្វើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាអាណត្តិទី២(២០២៤-២០២៧) ជាលទ្ធផលនៃការបោះឆ្នោតបានបង្ហាញថា៖

១. លោក **ឡេង ខៀវ** ទទួលបានលេខរៀងទី១ មានសំឡេងឆ្នោតគាំទ្រ ១៤៣សំឡេង
២. លោកស្រី **ស៊ឹម សៀមនី** ទទួលបានលេខរៀងទី២ មានសំឡេងឆ្នោតគាំទ្រ ១១៩សំឡេង។ ដូច្នេះ លោក **ឡេង ខៀវ** នឹងក្លាយជាប្រធានក្រុមប្រឹក្សាភិបាល ហើយលោកស្រី **ស៊ឹម សៀមនី** នឹងក្លាយជាអនុប្រធានក្រុមប្រឹក្សាភិបាល សម្រាប់អាណត្តិទី២ (២០២៤-២០២៧)។

**តារាងទី១៖** លទ្ធផលនៃការរាប់សន្លឹកឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាល

| លេខរៀងបេក្ខជន | ឈ្មោះបេក្ខជន | ចំនួនសន្លឹកឆ្នោត | លេខលំដាប់ |
|---|---|---|---|
| ១ | លោក ជា សំបូរ | ៩៥ | ៨ |
| ២ | លោក ចាន់ ថានី | ៩៥ | ៨ |
| ៣ | លោក មួង ដារ៉ាវី | ៧២ | |
| ៤ | អ្នកស្រី ហាក់ សេងថា | ៥៦ | |
| ៥ | លោក ហម ងួន | ១០៨ | ៤ |
| ៦ | អ្នកស្រី យ៉ាន ធីតា | ១០៣ | ៥ |
| ៧ | លោក រី ខេមឫទ្ធិ | ៦៨ | |
| **៨** | **អ្នកស្រី ស៊ឹម សៀមនី** | **១១៩** | **២** |
| ៩ | លោក ហៀក អេងឡាយ | ៨០ | ១០ |
| ១០ | លោក សៀវ ហួត | ១០០ | ៦ |
| **១១** | **លោក ឡេង ខៀវ** | **១៤៣** | **១** |

| លេខរៀងបេក្ខជន | ឈ្មោះបេក្ខជន | ចំនួនសន្លឹកឆ្នោត | លេខលំដាប់ |
|---|---|---|---|
| ១២ | លោក លាង បញ្ញា | ៩៨ | ៧ |
| ១៣ | លោក សៀ សេងហ៊ាប | ១១០ | ៣ |

## ២.២ កិច្ចប្រជុំឆ្លុះបញ្ចាំងប្រចាំឆ្នាំ២០២៣

ថ្ងៃទី២៤-២៦ ខែមករា ឆ្នាំ២០២៤ សមាគមបានរៀបចំកិច្ចប្រជុំឆ្លុះបញ្ចាំងការងារប្រចាំឆ្នាំ រវាងក្រុមប្រឹក្សាភិបាល និងបុគ្គលិកចំនួន ៣ថ្ងៃនៅខេត្តកំពត។

កិច្ចប្រជុំនេះទទួលបានលទ្ធផលដូចជា៖ ១.ឆ្លុះបញ្ចាំងលទ្ធផលការងារឆ្នាំ២០២៣ និងរៀបចំផែនការឆ្នាំ២០២៤ ២.បង្កើតជាវេទិកាមួយក្នុងការទទួលស្គាល់ការខិតខំរបស់បុគ្គលិកដែលបានប្ដេជ្ញាចិត្ត និងការចូលរួមចំណែកឱ្យចក្ខុវិស័យ និងបេសកកម្មរបស់សមាគមទទួលបានជោគជ័យ ៣.បង្កើនទំនាក់ទំនងឱ្យកាន់តែប្រសើររវាងបុគ្គលិក និងក្រុមប្រឹក្សាភិបាល ៤.ពិភាក្សាអំពីការរៀបចំសន្និបាតលើកទី១២ ៥.វាយតម្លៃការងាររបស់សមាគមប្រចាំឆ្នាំ២០២៣ និង ៦.ទស្សនកិច្ចសិក្សានៅរោងចក្រផលិតទឹកស្អាតម្លេច របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ៕

## ២.៣ កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាភិបាល

នៅក្នុងត្រីមាសទី១ ឆ្នាំ២០២៤ សមាគមបានរៀបចំកិច្ចប្រជុំវិសាមញ្ញ តាមរយៈអនឡាញខល (Zoom Meeting) ជាមួយក្រុមប្រឹក្សាភិបាលចំនួន ២លើក៖

១. **លើកទី១៖** ថ្ងៃទី១ ខែមីនា ឆ្នាំ២០២៤ មានសមាសភាពចូលរួមពីសមាជិកក្រុមប្រឹក្សាភិបាលជាប់ឆ្នោត គណៈកម្មការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាល អាណត្តិទី២ សម្រាប់នីតិបុគ្គល និងថ្នាក់ដឹកនាំសមាគម។ ជាលទ្ធផល **លោក សៀ សេងហ៊ាប** ត្រូវបានជ្រើសរើសជាហេរញ្ញិក និង**លោក ហៀក អេងឡាយ** ជាសមាជិកក្រុមប្រឹក្សាភិបាល ជំនួស **លោក ហម ងួន** ដែលបានសុំលាឈប់។ ជំហានបន្ទាប់សមាគមត្រូវរៀបចំឯកសារស្នើទៅក្រសួងមហាផ្ទៃសុំទទួលស្គាល់សមាសភាពថ្មីនៃរចនាសម្ព័ន្ធក្រុមប្រឹក្សាភិបាលសមាគម អាណត្តទី២សម្រាប់នីតិបុគ្គល ក្នុងអំឡុងពេល១៥ថ្ងៃនៃថ្ងៃធ្វើការក្រោយពីសន្និបាត កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤។



២. **លើកទី២៖** ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ ក្រុមប្រឹក្សាភិបាលបានសម្រេចជាឯកច្ឆន្ទអំពី**«គោលនយោបាយគាំទ្រប្រាក់ចុះបេសកកម្មការងារ និងចូលរួមប្រជុំតាម ខេត្តរបស់ក្រុមប្រឹក្សាភិបាល»** ព្រមទាំងបានធ្វើបច្ចុប្បន្នភាពអំពីអាសយដ្ឋានរបស់ក្រុមប្រឹក្សាភិបាល។

## ២.៣ សំណើសុំការអនុញ្ញាតទទួលស្គាល់សមាសភាពថ្មីនៃរចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាភិបាលសមាគម

នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៤ សមាគមបានរៀបចំឯកសារស្តីពីសមាសភាពថ្មីនៃរចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាភិបាល សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា អាណត្តិទី២ សម្រាប់នីតិបុគ្គល ជូនទៅ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីទទួលស្គាល់។



*រូបភាពទី 3-កិច្ចប្រជុំឆ្លុះបញ្ចាំងប្រចាំឆ្នាំ២០២៣*



*រូបភាពទី 4-ទស្សនកិច្ចសិក្សានៅរោងចក្រផលិតទឹកស្អាតម្លេច*

## ៣. ការងារជាមួយសមាជិក

### ៣.១ កិច្ចប្រជុំថ្នាក់តំបន់

នៅក្នុងត្រីមាសទី១នេះ សមាគមបានរៀបចំកិច្ចប្រជុំថ្នាក់តំបន់សម្រាប់ប្រតិបត្តិករជាសមាជិកសមាគម មកពីខេត្តបន្ទាយមានជ័យ ឧត្តរមានជ័យ ព្រះវិហារ កំពង់ធំ និងសៀមរាប។ កិច្ចប្រជុំបានរៀបចំនៅសណ្ឋាគារផៅរ៉ាដាយ ក្រុងសៀមរាប ក្រោមអធិបតីភាព លោក **ជា វុធឡុង** ប្រធានមន្ទីរ ឧរបន ខេត្តសៀមរាប និង លោក **ឡេង ខៀវ** ប្រធានក្រុមប្រឹក្សាភិបាលសមាគម។

កិច្ចប្រជុំនេះមានអ្នកចូលរួមសរុបចំនួន ៧៧នាក់(ស្រី ១៦នាក់) រួមមាន៖ ថ្នាក់ដឹកនាំ និងមន្ត្រីនៃមន្ទីរ ឧរបន ខេត្តសៀមរាប អង្គការ Water.org ក្រុមប្រឹក្សាភិបាល បុគ្គលិកសមាគម តំណាងធនាគារ តំណាងក្រុមហ៊ុនចំនួន៧ ព្រមទាំងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតចំនួន ២៨ស្ថានីយ។ កិច្ចប្រជុំថ្នាក់តំបន់ទទួលបានការឧបត្ថម្ភពី អង្គការ Water.org និងដៃគូសហការឧបត្ថម្ភដោយ៖ ១.ក្រុមហ៊ុន ធីស៊ីយូ (T.C.U Polys Enterprise) ២.ក្រុមហ៊ុន ភ្នំពេញប្លាស្ទិច (PP Plastic Product) ៣.ក្រុមហ៊ុន LESSO Trading Cambodia ៤.ក្រុមហ៊ុន យូភីជីផាយ (U P G Pipe Co., Ltd) ៥.ក្រុមហ៊ុន អ៊ិចវ៉តធើ (X-Water Technology Co., Ltd) ៦.ក្រុមហ៊ុន ផាមអេឡិចទ្រិកសូលូសិន (Pump Electric Solution Co., LTD), និង ៧.ក្រុមហ៊ុន ឃិនតិច តិចណូឡូជី (KINTEK Technology Co., Ltd)។



*រូបភាពទី 5-កិច្ចប្រជុំថ្នាក់តំបន់នៅខេត្តសៀមរាប*

កិច្ចប្រជុំថ្នាក់តំបន់នេះមានគោលបំណង៖

១. ស្តាប់សំឡេងរបស់សមាជិក ស្វែងរកដំណោះស្រាយជូនសមាជិក

២. ការផ្សព្វផ្សាយពី«គម្រោងហិរញ្ញប្បទានធនាគារសហគ្រាសធុនតូច និងមធ្យម» និងការជ្រើសរើសប្រតិបត្តិករសម្រាប់គម្រោង«ការកែលម្អលទ្ធភាពទទួលបានហិរញ្ញប្បទានរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជននៅកម្ពុជា ដើម្បីពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាត»

៣. បង្កើនទំនាក់ទំនងជាមួយមន្ទីរ ឧរបន សមាជិកសមាគម និងដៃគូអភិវឌ្ឍន៍

៤. បច្ចុប្បន្នភាពពីសមាគមច្បាប់គតិយុត្តនានាទាក់ទងទៅនឹងវិស័យទឹកស្អាត និងការចែករំលែកចំណេះដឹង បទពិសោធន៍ ព័ត៌មាន និងបច្ចេកវិទ្យាថ្មីៗ។



*រូបភាពទី ៦-បទបង្ហាញស្តីពីលទ្ធផលពិភាក្សាក្រុម*

### ៣.២ កិច្ចគាំពារសមាជិក

ក្នុងត្រីមាសទី១ ឆ្នាំ២០២៤ សមាគមបានគាំទ្រ និងសម្របសម្រួលកិច្ចប្រជុំដោះស្រាយបញ្ហារបស់សមាជិកបានចំនួន ១ករណី៖

ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៤ ថ្នាក់ដឹកនាំសមាគមបានជួបប្រជុំជាមួយ ម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតឃុំព្រៃករំដេង **លោក យឹម សំអឿន** និង កូនប្រុសរបស់គាត់ ដើម្បីពិគ្រោះយោបល់ និងពិភាក្សាលើបញ្ហាក្រុមហ៊ុនឈូសឆាយផ្លូវធ្វើឱ្យខូចខាតប្រព័ន្ធបណ្តាញទុយោរបស់ស្ថានីយ។ ក្នុងកំឡុងពេលនៃកិច្ចពិភាក្សា សមាគមបានជូនជាមតិយោបល់ដែលទាក់ទងទៅនឹងអង្គហេតុ ព្រមទាំងបានស្នើឱ្យលោក យឹម សំអឿន ប្រមូលនូវឯកសារព្រមទាំងភស្តុតាងនានា ដើម្បីដាក់ជូនទៅអាជ្ញាធរឃុំ ស្រុក មន្ទីរ និងក្រសួង ឧរបន ដើម្បីជួយដោះស្រាយនូវបញ្ហានេះ។ ជាលទ្ធផល សមាគមបានជួយរៀបចំឯកសារជូនស្ថានីយផ្គត់ផ្គង់ទឹកស្អាតឃុំព្រៃករំដេង សម្រាប់ដាក់ជូនទៅក្រសួង ឧរបន រួចរាល់ហើយ។




*រូបភាពទី 7-សកម្មភាពឈូសឆាយរបស់ក្រុមហ៊ុនដែលបណ្តាលឱ្យប៉ះពាល់ដល់បណ្តាញបំពង់ទឹកស្អាត*

### ៣.៣ ការគាំទ្រជំនួយបច្ចេកទេស

ក្នុងត្រីមាសទី១ នៃឆ្នាំ២០២៤ បុគ្គលិកបច្ចេកទេសសមាគម បានផ្តល់ជំនួយបច្ចេកទេសជូនដល់សមាជិករួមមាន៖ ធ្វើដ្យាតេស្តទឹកឆៅជូនដល់ប្រតិបត្តិករចំនួន ១ ស្ថានីយ និងបានប្រឹក្សាយោបល់លើបច្ចេកទេសផលិតទឹកស្អាត និងត្រួតពិនិត្យគុណភាពទឹកជូនដល់ប្រតិបត្តិករចំនួន ៧ស្ថានីយផ្សេងទៀត។

### ៣.៤ ដំណើរកម្សាន្តប្រចាំឆ្នាំរបស់សមាជិក

ថ្ងៃទី២៧-២៩ ខែមីនា ឆ្នាំ២០២៤ សមាគមបានរៀបចំដំណើរកម្សាន្តប្រចាំឆ្នាំសម្រាប់សមាជិកសមាគម ទៅទស្សនា កោះត្រល់ ប្រទេសវៀតណាមចំនួន ៣ថ្ងៃ។ នៅក្នុងដំណើរកម្សាន្តនេះ មានអ្នកចូលរួមសរុបចំនួន ២១នាក់ (ស្រី ១០នាក់) ក្នុងនោះមានប្រតិបត្តិករ ១៩ស្ថានីយ និង១ក្រុមហ៊ុន។




*រូបភាពទី 8-ដំណើរកំសាន្តរបស់សមាជិក*



*រូបភាពទី 9-ដំណើរកំសាន្តរបស់សមាជិក*

## ៤. កម្មវិធីកសាងសមត្ថភាពសមាជិក

នៅក្នុងត្រីមាសទី១ សមាគមបានរៀបចំវគ្គបណ្តុះបណ្តាលជូនដល់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន បានចំនួន ៣វគ្គ រួមមាន៖

១. **វគ្គទី១៖** នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៤ វគ្គបណ្តុះបណ្តាលស្តីពី«ការគ្រប់គ្រងទឹកបាត់បង់ និងបច្ចេកទេសថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត» នៅភោជនីយដ្ឋានទន្លេបាសាក់ ២ រាជធានីភ្នំពេញ មានអ្នកចូលរួមសរុបចំនួន ៤៥នាក់ (ស្រី ៦នាក់)។

គោលបំណងនៃវគ្គបណ្តុះបណ្តាលរួមមាន៖

1)ពន្យល់បានពីបច្ចេកទេសនៃការសម្អាតទឹកចាប់ពីប្រភពទឹករហូតដល់អ្នកប្រើប្រាស់

2) រៀបរាប់បានពីបច្ចេកទេសសម្រាប់ប្រតិបត្តិការ និងការថែទាំ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និង

3) កំណត់បានពីបច្ចេកទេសគ្រប់គ្រងទឹកបាត់បង់ សម្រាប់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។



*រូបភាពទី 10-រូបថតអនុស្សាវរីយ៍សម្រាប់ក្រុមទី១*

២. **លើកទី២៖** នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤ វគ្គបណ្តុះបណ្តាលស្តីពី«ការគ្រប់គ្រងទឹកបាត់បង់ និងបច្ចេកទេសថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត» នៅភោជនីយដ្ឋានទន្លេបាសាក់ ២ រាជធានីភ្នំពេញ មានអ្នកចូលរួមសរុបចំនួន ៤០នាក់ (ស្រី ៨នាក់)។



*រូបភាពទី 11-រូបថតអនុស្សាវរីយ៍សម្រាប់ក្រុមទី២*

៣. **លើកទី៣៖** នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៤ វគ្គបណ្តុះបណ្តាលស្តីពី«វិធីសាស្ត្រធ្វើជ្យារតេស្ត និងការវិភាគគុណភាពទឹកស្អាត»។ វគ្គបណ្តុះបណ្តាលនេះរៀនទ្រឹស្តីនៅក្នុងសណ្ឋាគារសាន់វេ និងអនុវត្តផ្ទាល់នៅស្ថានីយផ្គត់ផ្គង់ទឹកស្អាតបែកចាន។ វគ្គបណ្តុះបណ្តាលនេះមានអ្នកចូលរួមសរុបចំនួន ១៨នាក់ (ស្រី ១នាក់)។



*រូបភាពទី 12-សកម្មភាពពិភាក្សាក្រុម*

ជាលទ្ធផលនៃវគ្គបណ្តុះបណ្តាល អ្នកចូលរួមអាច ១). រៀបរាប់បានពីដំណើរការធ្វើជ្យារតេស្ត និងការវិភាគគុណភាពទឹកស្អាត ២). រៀបរាប់បានពី ប៉ារ៉ាម៉ែត្រប្រចាំថ្ងៃ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ៣). រៀបរាប់បានពីផលប៉ះពាល់សារធាតុគីមីដែលមានក្នុងទឹក ៤). អនុវត្តការធ្វើជ្យារតេស្ត និងតេស្តគុណភាពទឹកស្អាត ៥). ទស្សនាប្រព័ន្ធសម្អាតទឹករបស់ស្ថានីយទឹកស្អាតបែកចាន និង ៦). ការចែករំលែកបទពិសោធន៍ល្អពីគ្នាទៅវិញទៅមក។



*រូបភាពទី 13-សកម្មភាពអនុវត្តការតេស្តគុណភាពទឹកស្អាត*



*រូបភាពទី 14-រូបថតអនុស្សាវរីយ៍នៅស្ថានីយទឹកស្អាតបែកចាន*

# ៥. កិច្ចសហប្រតិបត្តិការ

## ៥.១ សិក្ខាសាលាស្តីពីទឹកស្អាត និងប្រព័ន្ធអនាម័យ កម្ពុជា-ជប៉ុន ២០២៤

កាលពីថ្ងៃទី១៦-១៧ ខែមករា ឆ្នាំ២០២៤ សមាគមបានសហការសម្របសម្រួលរៀបចំសិក្ខាសាលាស្តីពីទឹកស្អាត និងប្រព័ន្ធអនាម័យ កម្ពុជា ជប៉ុន ២០២៤ (លើកទី១៦) ជាមួយសមាគមអាជីវកម្មទឹកក្រៅប្រទេស ក្រុងគីតាយូស៊ូ (KOWBA) ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ឧវបន) អង្គភាពទឹកស្អាត និងប្រព័ន្ធអនាម័យទីក្រុងគីតាយូស៊ូ ។



*រូបភាពទី 15-សិក្ខាសាលាស្តីពីទឹកស្អាត និងប្រព័ន្ធអនាម័យ កម្ពុជា-ជប៉ុន*

សិក្ខាសាលានេះមានការអញ្ជើញចូលរួមពី ថ្នាក់ដឹកនាំ និងមន្ត្រីរបស់ក្រសួង ឧវបន មន្ត្រីស្ថានទូតជប៉ុន មន្ត្រីក្រសួងសុខាភិបាល ការងារ និងសង្គមកិច្ចជប៉ុន មន្ត្រីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ប្រតិភូអង្គភាពទឹកស្អាត និងប្រព័ន្ធអនាម័យទីក្រុងគីតាយូស៊ី និង ប្រតិភូសមាគមអាជីវកម្មទឹកក្រៅប្រទេស ក្រុងគីតាយូស៊ី ប្រតិភូក្រុមហ៊ុនឯកជនជប៉ុន ក្រុមប្រឹក្សាភិបាលសមាគម បុគ្គលិកសមាគម និង ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត។

សិក្ខាសាលាមានគោលដៅផ្តល់បច្ចុប្បន្នភាពវិស័យទឹកស្អាតរបស់កម្ពុជា បញ្ហាប្រឈម ការប្រែក្លាយពីអង្គភាពរដ្ឋាករទឹកជាសហគ្រាសសាធារណៈ និងការពិភាក្សាពីកិច្ចដំណើរការប្រតិបត្តិការរបស់រដ្ឋាករទឹកសាធារណៈ និងប្រតិបត្តិករឯកជន។ ក៏ដូចជាបង្ហាញពីបច្ចេកវិទ្យាថ្មីៗសម្រាប់ការគ្រប់គ្រងទឹកស្អាត តាមរយៈការធ្វើបទបង្ហាញ និងការតាំងពិព័រណ៍ពីក្រុមហ៊ុនជប៉ុន ។ ក្នុងកំឡុងសិក្ខាសាលានេះក៏មានការធ្វើបទបង្ហាញស្តីពី៖

១. ការផ្គត់ផ្គង់ទឹកស្អាតកម្ពុជាៈ ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈមដោយ **ឯកឧត្តម តន់ សុខជា** អគ្គនាយក នៃអគ្គនាយកដ្ឋានទឹកស្អាត ឧវបន

២. ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈមរបស់រដ្ឋាករទឹកសាធារណៈខេត្តស្វាយរៀង

៣. បញ្ហាប្រឈមក្នុងការពង្រីកសេវាផ្គត់ផ្គង់ទឹកស្អាត និងអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដោយសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា

៤. ការបង្ហាញពីសមិទ្ធិផលរបស់ក្រុមហ៊ុនឯកជន ជប៉ុនទាំង១១

៥. ការចែករំលែកបទពិសោធន៍របស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ឡេង ខៀវ។

ទន្ទឹមនេះសិក្ខាសាលាក៏បានបែងចែកសិក្ខាកាមជា ៤ក្រុមដើម្បីពិភាក្សា និងការធ្វើបទបង្ហាញទៅលើ៖ ក្រុមទី១ ទ្រព្យ ក្រុមទី២ ប្រតិបត្តិការ ក្រុមទី៣ ការគ្រប់គ្រងទិន្នន័យ និងក្រុមទី៤ អាជីវកម្ម។




*រូបភាពទី 16-កិច្ចពិភាក្សាបញ្ហាប្រឈមក្នុងការពង្រីកសេវាផ្គត់ផ្គង់ទឹកស្អាតនិងអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត*

សិក្ខាសាលាក៏បានធ្វើការពិភាក្សាជាក្រុមដោយផ្តោតលើ៖ ស្ថានភាពលើវិស័យផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជា និងប្រព័ន្ធទឹកស្អាតដែលមានបច្ចេកវិទ្យាទំនើប។ ក្រោយបិទបញ្ចប់សិក្ខាសាលា សមាគមក៏បានសម្របសម្រួលទស្សនកិច្ចសិក្សាទៅស្ថានីយទឹកស្អាត ឡេងខៀវ ព្រែកអំបិល សម្រាប់ក្រុមការងារមកពីប្រទេសជប៉ុនផងដែរ។

### ៥.២ សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ របស់ក្រសួង ឧវបន

នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៤ លោក លឹម មិញ នាយកប្រតិបត្តិ និង លោក សៀ សេងហ៊ាប ហេរញ្ញិកនៃសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា បានចូលរួមសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងនោះដែរ លោក លឹម មិញ ក៏បានចូលរួមជាវាគ្មិនក្នុងការពិភាក្សាក្រោមប្រធានបទ «ការបំពេញតួនាទីភាពជាដៃគូសហប្រតិបត្តិការដើម្បីសម្រេចគោលដៅទី ៦ នៃក្របខណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា»។



*រូបភាពទី 17-ការបើកអង្គសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ របស់ក្រសួង ឧវបន*



*រូបភាពទី 18-កិច្ចពិភាក្សាប្រធានបទការបំពេញតួនាទីភាពជាដៃគូសហប្រតិបត្តិការដើម្បីសម្រេចគោលដៅទី ៦*

## ៦. ការងារគម្រោង

### ៦.១ ការកែលម្អលទ្ធភាពទទួលបានហិរញ្ញប្បទានប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជននៅកម្ពុជាដើម្បីពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាត

#### ៦.១.១ ការពង្រឹងសមត្ថភាពប្រតិបត្តិករលើផ្នែកបច្ចេកទេស

នៅក្នុងត្រីមាសទី១ នេះសមាគមបានសម្របសម្រួលការងារបច្ចេកទេសមួយចំនួនដូចខាងក្រោម៖

១. តាមដានការតេស្តគុណភាពទឹកស្អាតរបស់សមាជិកក្នុងគម្រោង និងបានផ្តល់យោបល់កែតម្រូវលើការតេស្តគុណភាពទឹកស្អាតលើប៉ារ៉ាម៉ែត្រប្រចាំថ្ងៃជូនសមាជិក។

២. រៀបចំផែនការចុះបង្វឹកផ្នែកបច្ចេកទេសជូនជូនសមាជិកផ្តល់ទម្រង់របាយការណ៍ផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុជូនប្រតិបត្តិករក្នុងគម្រោង និងលើកទឹកចិត្តពួកគាត់រៀបចំរបាយការណ៍នេះ។

៣. ជួយពិនិត្យ និងផ្តល់យោបល់ជូនស្ថានីយទឹកស្អាតតេជោមានជ័យលើរបាយការណ៍ផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ។

៤. សម្របសម្រួលទិញឧបករណ៍ជ្យាតេស្តជូនប្រតិបត្តិករថ្មី ដោយមានការចូលរួមបដិភាគពីគម្រោង និងប្រតិបត្តិករផ្ទាល់។

៦. សម្របសម្រួលតំណាងអង្គការ Water.org ទស្សនកិច្ចសិក្សាទៅកាន់ស្ថានីយទឹកស្អាតសូទ្រនិគម។

### ៦.១.២ ការពង្រឹងសមត្ថភាពប្រតិបត្តិករលើប្រព័ន្ធគណនេយ្យ

សមាគមបានសម្របសម្រួលការជួបប្រជុំរវាងប្រតិបត្តិករ និងក្រុមហ៊ុន EAST WING AUTIDTING & CONSULTING CO., LTD ដើម្បីពិភាក្សាអំពីបញ្ហាប្រឈមការបើកសមតុល្យដើមគ្រា។




*រូបភាពទី 19-កិច្ចប្រជុំតាមអនឡាញ*

ជាលទ្ធផលក្រុមហ៊ុននេះបានសហការជាមួយសមាគមក្នុងការជួយដល់សមាជិកគម្រោងដើម្បីអាចចាប់ផ្តើមការងារគណនេយ្យបាន។ ក្រុមហ៊ុនបានជ្រើសរើសប្រតិបត្តិករចំនួន ៥ស្ថានីយ ដើម្បីគាំទ្រជំនួយបច្ចេកទេសក្នុងការពិនិត្យទិន្នន័យហិរញ្ញវត្ថុ បើកសមតុល្យដើមគ្រាសម្រាប់ឆ្នាំ២០២៣ និងបញ្ចូលប្រតិបត្តិកាហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៣ ចូលក្នុងប្រព័ន្ធគណនេយ្យពេញមួយឆ្នាំជូនប្រតិបត្តិករទាំងប្រាំ (៥) ដោយឥតគិតថ្លៃ។

ស្ថានីយទាំង៥ ដែលបានជ្រើសរើសចូលរួមក្នុងការរៀបចំឯកសារ រួមមាន៖

១. ស្ថានីយផ្គត់ផ្គង់ទឹកស្អាតស្វាយជ្រះ

២. ស្ថានីយផ្គត់ផ្គង់ទឹកស្អាតចំការលើ

៣. ស្ថានីយផ្គត់ផ្គង់ទឹកស្អាតលីហេង

៤. ស្ថានីយផ្គត់ផ្គង់ទឹកស្អាតកន្ទួត

៥. ស្ថានីយផ្គត់ផ្គង់ទឹកស្អាតសូទ្រនិគម

### ៦.១.៣ ការគាំទ្រលើការងារស្នូលរបស់សមាគម

គម្រោងបានគាំទ្របន្ថែមដល់សន្និបាតលើកទី១២ របស់សមាគមដែលរៀបចំនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤។

គម្រោងក៏បានគាំទ្រដល់កិច្ចប្រជុំថ្នាក់តំបន់សម្រាប់សមាជិកជាប្រតិបត្តិករមកពីខេត្តបន្ទាយមានជ័យ ឧត្តរមានជ័យ ព្រះវិហារ កំពង់ធំ និងសៀមរាប ដែលរៀបចំនៅខេត្តសៀមរាបកាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤ ក្រោមអធិបតីភាព លោកប្រធាន មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ខេត្តសៀមរាប និង លោក ឡេង ខៀវ ប្រធានក្រុមប្រឹក្សាភិបាល។ ជាលទ្ធផលសមាជិកបានរៀនសូត្របន្ថែមអំពីតួនាទី និងការទទួលខុសត្រូវរបស់ប្រតិបត្តិករដែលមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត និងប្រកាសអនុញ្ញាត ព្រមទាំងមានទទួលបានចំណេះដឹងថ្មីៗលើបច្ចេកវិទ្យាក្នុងវិស័យទឹកស្អាត ការធ្វើទីផ្សារជំរុញកំណើតតំណ លក្ខខណ្ឌនានាក្នុងការទទួលបានហិរញ្ញប្បទាន និងលក្ខខណ្ឌដើម្បីចូលរួមសិក្សាផែនការមេដែលគាំទ្រដោយអង្គការ Water.org ផងដែរ។

### ៦.១.៤ កិច្ចប្រជុំជាមួយស្ថាប័នហិរញ្ញវត្ថុ

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា និងតំណាងអង្គការ Water.org បានសម្របសម្រួលអញ្ជើញប្រតិបត្តិករមួយស្ថានីយ ដើម្បីស្វែងយល់អំពី Water Equity និងស្វែងរកឱកាសទទួលបានមូលនិធិពី Water Equity។ ជាលទ្ធផលតំណាងខាង Water Equity នឹងពិចារណាសិក្សាលើស្ថានីយនេះ។

ក្នុងនោះផងដែរ សមាគម និងអង្គការ water.org បានរៀបចំជាសេចក្តីប្រកាសស្វែងរកក្រុមហ៊ុនទីប្រឹក្សា ដើម្បីរៀបចំផែនការមេសម្រាប់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត និង

ប្រកាសជ្រើសរើសប្រតិបត្តិករចំនួន ៦ស្ថានីយ ដើម្បីចូលរួមក្នុងគម្រោងសិក្សាផែនការមេនេះផងដែរ។

គោលបំណងសំខាន់នៃការសិក្សានេះ គឺបង្កើតផែនការមេអាជីវកម្មចំនួន ៦ ដោយមានផែនការវិនិយោគច្បាស់លាស់។ ក្នុងនោះមានដែនកំណត់ការងារសំខាន់ៗដូចខាងក្រោម៖

១. ពិនិត្យមើលផែនការអាជីវកម្មដែលមានស្រាប់របស់ប្រតិបត្តិករ ដើម្បីរៀបចំផែនការមេអាជីវកម្មសម្រាប់រយៈពេល ៥ឆ្នាំ ដោយមានផែនការវិនិយោគច្បាស់លាស់។
២. ការសិក្សាវិស្វកម្មលម្អិត (DED) លើការពង្រីកបំពង់ និងការពង្រីករោងចក្រប្រព្រឹត្តិកម្មទឹកស្អាត ដើម្បីឱ្យមានសមត្ថភាពចែកចាយ និងផ្គត់ផ្គង់បរិមាណទឹកស្អាតគ្រប់គ្រាន់ទៅតាមតម្រូវការនៃការប្រើប្រាស់ទឹកស្អាត(អតិថិជនលំនៅដ្ឋាន ពាណិជ្ជកម្ម និងឧស្សាហកម្ម) បច្ចុប្បន្ន និងសម្រាប់តម្រូវការទឹក៥ឆ្នាំខាងមុខ។
៣. វាយតម្លៃការបាត់បង់ទឹកតាមរយៈការលេចធ្លាយទឹកការកំណត់អត្តសញ្ញាណ និងបង្កើតផែនការកាត់បន្ថយការបាត់បង់ទឹក រួមទាំងការវិនិយោគ។
៤. បង្កើតផែនការមេអាជីវកម្មរយៈពេល ៥ឆ្នាំ ដោយមានផែនការវិនិយោគច្បាស់លាស់។
៥. ប្រឹក្សាយោបល់លើទិដ្ឋភាពបច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់ប្រតិបត្តិករចំនួន ៦ ស្ថានីយដើម្បីឱ្យមានលទ្ធភាពទទួលបានមូលនិធិពីអង្គការមិនមែនរដ្ឋាភិបាលនានា។

### ៦.១.៥. ការសម្របសម្រួលកម្ចីរវាងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងស្ថាប័នហិរញ្ញវត្ថុ

សមាគមបានសម្របសម្រួលកម្ចីជូនប្រតិបត្តិករចំនួន ១ស្ថានីយ ទទួលបានការអនុម័តកម្ចីពីធនាគារសហគ្រាសធុនតូច និងមធ្យម (SME) ដែលមានទំហំទឹកប្រាក់ចំនួន ៩៥០.០០០.០០០៛សម្រាប់គោលបំណង៖ ១)ពង្រីកបណ្តាញបំពង់ ៥២.០០០.០០០៛ ២)ដំឡើងម៉ូទ័រុញ និងទូបញ្ជា ៥៦.០០០.០០០៛ ៣)ដំឡើងប្រព័ន្ធថាមពលព្រះអាទិត្យ ៥៦.០០០.០០០ ឬ ៤)ចំណាយលើពលកម្ម គ្រឿងតំណ និងកែលម្អអាងប្រព្រឹត្តកម្ម ១១១.៥៥៩.៣០០៛ និង៥) ចំណាយលើគោលបំណងផ្សេងៗ ៦៧៤.៤៤០.៧០០៛។

ផ្អែកលើគោលនយោបាយរបស់ធនាគារ SME នឹងគិតអត្រាការប្រាក់អប្បបរមាចំនួន ៥.៨៨% ក្នុងមួយឆ្នាំសម្រាប់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ដោយយោងលើអនុស្សរណៈយោគយល់គ្នារវាងសមាគម CWA និងធនាគារ SME ដូច្នេះខាងធនាគារ SME នឹងបញ្ចុះតម្លៃលើអត្រាការប្រាក់បន្ថែមចំនួន ០.២៥% ក្នុងមួយឆ្នាំ និងប្រតិបត្តិករនេះ គាត់យកកម្ចីជាប្រាក់រៀល ដូច្នេះគាត់ទទួលបានការបញ្ចុះតម្លៃលើការប្រាក់ចំនួន០.២៥% ក្នុងមួយឆ្នាំថែមទៀត។

### ៦.២ គម្រោង«សហគមន៍ដឹកនាំទឹកស្អាត និងអនាម័យធន់នឹងអាកាសធាតុប្រកបដោយបរិយាប័ន្ន» (EMW)

នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ បុគ្គលិកសមាគមបានចូលរួមសម្របសម្រួលជាមួយអង្គការ EMW CDRI ISF-UTS ក្នុងការសម្ភាសន៍អាជ្ញាធរមូលដ្ឋានក្នុងសង្កាត់រលាប ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។ ការសម្ភាសន៍នេះផ្តោតលើដំណើរការបង្កើតក្រុម និងការអនុវត្តន៍ផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ។ កិច្ចសម្ភាសន៍នេះមានអ្នកចូលរួមសរុបចំនួន៤៧នាក់ ស្រី១៧នាក់។



*រូបភាពទី 20-កិច្ចសម្ភាសន៍ក្រុមគោលដៅ*

### ៦.៣ គម្រោង «ការពង្រឹងប្រព័ន្ធផែនការគ្រប់គ្រងធនធានទឹក សម្រាប់សេវាកម្មទឹកស្អាត និងអនាម័យធន់នឹងអាកាសធាតុ ប្រកបដោយបរិយាប័ន្ននៅក្នុងប្រទេសកម្ពុជា»

សមាគមបានផ្តល់វគ្គបង្វឹកផ្ទាល់ដល់ស្ថានីយទឹកស្អាតចំនួនពីរលើប្រធានបទស្តីពី «ផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុសម្រាប់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតកម្ពុជា»។

ជាលទ្ធផល ស្ថានីយទាំងពីរបានរៀបចំផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុសម្រាប់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតសម្រាប់ស្ថានីយរបស់ពួកគាត់រៀងខ្លួន ដោយមានការផ្តល់យោបល់ និងឆ្លុះបញ្ចាំងពីអ្នកពាក់ព័ន្ធទៅលើមុខសញ្ញាគ្រោះថ្នាក់ទៅលើប្រព័ន្ធប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។ ជាងនេះទៅទៀត អ្នកពាក់ព័ន្ធទាំងអស់បានស្វែងយល់បន្ថែមពីផែនការរបស់ស្ថានីយនីមួយៗ ក្នុងការការគ្រប់គ្រងធនធានទឹក និងប្រប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតទាំងមូល។

១. ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៤ រៀបចំនៅស្ថានីយផ្គត់ផ្គង់ទឹកស្អាតត្បែងខ្ពស់ មានអ្នកចូលរួមសរុបចំនួន១០នាក់ ស្រី៥នាក់ ដែលអញ្ជើញមកពីរដ្ឋបាលឃុំត្បែងខ្ពស់ រដ្ឋបាលឃុំសេដ្ឋី តំណាងអង្គការជនមានពិការភាពស្រុកសាមគ្គីមានជ័យ។



*រូបភាពទី 21-សកម្មភាពបង្វឹកនៅស្ថានីយទឹកស្អាតត្បែងខ្ពស់*



*រូបភាពទី 22-ស្វែងយកពីដំណើរការផលិតទឹកនៅស្ថានីយទឹកស្អាតត្បែងខ្ពស់*

២. នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៤ រៀបចំនៅស្ថានីយផ្គត់ផ្គង់ទឹកស្អាតលង្វែក មានអ្នកចូលរួមសរុបចំនួន ៨នាក់ ស្រី២នាក់ ដែលអញ្ជើញមកពីរដ្ឋបាលឃុំស្វាយ តំណាងអង្គការជនមានពិការភាពស្រុកសាមគ្គីមានជ័យ និងស្ថានីយទឹកស្អាត។



*រូបភាពទី 23-ស្វែងយកពីដំណើរការផលិតទឹកនៅស្ថានីយទឹកស្អាតលង្វែក*